អ្នកនិពន្ធ និង អ្នកអាន

សេរីការ : មហាវិថីគ្មានទ្វារ រាបើកច្រកឱ្យអស់ផ្លូវតូចៗចូលបាន

ការសរសេរ គឺដូចជាអ្នកធ្វើនាវាចរណ៍ តែម្នាក់ឯង។ មានថ្ងៃខ្លះ គ្មានខ្យល់ទាល់តែសោះ ដែលតម្រូវយកច្រវាទូក ចែវគាស់ទឹកឱ្យទូកក្តោងលឿនទៅមុខ ដូចគ្នា យកដងប៉ាកកា គាស់ក្រដាស ឬ ម្រាមដៃ ខ្វារក្តារចុចកុំព្យូទ័រ ដើម្បីបំផុះចេញ នូវគំនិត ដែលចង់សរសេរ។ មានថ្ងៃខ្លះ មានជំនោរ បក់តិចៗ បំផុះចេញ នូវគំនិតដង្ហែគ្នា ក្រងជាប្រយោគ បង្កើតជាចង្កោមនៃអត្ថចិន្តាច្បាស់លាស់ និង ត្រឹមត្រូវគួរទុកចិត្ត។ មានថ្ងៃខ្លះ មានព្យុះសង្ឆរា ផ្ទួល នូវគោលគំនិតដើម នាំធ្លាក់ទៅក្នុងកំហឹងច្រឡោត នៃការតស៊ូអារម្មណ៍នាំដុតសតិ អោយកលហ ពិរោធ ហួសពីការនឹកស្មាន ប្រៀបដូចជាកំពុងក្រចៅចិត្ត ជាងកំពុងសរសេរ។ ហើយបន្ទាប់មក មានរជនី មានព្រះចន្ទ ពេញបូណ៌មី ហើយនៅពេលនោះ ប្រាជ្ញាផុស ធ្វើឱ្យរីករាយគំនិតដូចខ្យល់រាត្រីស្នាបលៀវ[1] ឱ្យរសើប គឺជាពេលវេលានៅក្នុងការស្រវឹង នៃព្រលឹង ដែលឆក់សតិអ្នកសរសេរ ឱ្យមានជំនឿមួយរយ:ថា ពាក្យមួយដែលកំពុងសរសេរ វានឹងអាចប្តូរពិភពលោកបាន។ ជាទូទៅ ការសរសេរ គឺជាប្រតិព័ន្ធ នូវសុខុមាភាព តែក៏ជាសេចក្តីរីករាយ ជា ទាសា ទាសី ក្នុងការបំរើអារម្មណ៍ នៃអ្នក

[1] លៀវ : ខ្សែដងសារក្តោង។

អ្នកនិពន្ធ និង អ្នកអាន

អានៃនោះដែរ។ តែការសរសេរ ក៏ជួបប្រទះ ញ្ជីកញ្ជាយនឹង មតិ ប្រឆាំង ព្រោះជា ប្រធានបទ ជាសង្គ្រាមជ្រ៉ាកា ឬ មានភាព ចម្រូងចម្រាស។ តែអ្នកនិពន្ធ ត្រូវរក្សាគោលគំនិត និង រចនា បថ របស់ខ្លួន ដោយគ្មានចិត្តអរិភូត ព្រោះទស្សនៈ នៃបដិវាទ កម្ម វាជាទ្រព្យ និង ភក្សា នៃប្រាជ្ញា។ តែអ្នកអាន ក៏ត្រូវមាន សតិសម្បជញ្ញៈថា បើបានអានហើយ រួចជួបប្រទះ នូវមតិ វិបរិតនឹងខ្លួន សុំកុំឱ្យមាន សេចក្ដីក្រែវក្រោធក្នុងចិត្ត ព្រោះ ខ្លួនមាន សេរីភាពគ្រប់បែបយ៉ាងនឹង អាន ឬ មិនអាន។ កិច្ច នៃការអាន ជាការទទួលខុសត្រូវផ្ទាល់ខ្លួន, ដូច្នេះកុំខឹង ព្រោះវា គ្មានប្រយោជន៍ អ្វីនោះឡើយ, ផ្ទុយទៅវិញ គួរយកវាមក ពិនិស្ច័យ ដើម្បីរកតម្លៃ នូវសិល្ប នៃស្នាដៃ របស់អ្នកនិព័ន្ធ។ ការសរសេរ នាំបង្កើត នូវការស្រមៃគ្រប់បែបយ៉ាង នៅក្នុងអារ ម្មណ៍ នៃអ្នកអាន ជួនកាលវាផ្ដល់ នូវឫទ្ធានុភាព នៃសុភមង្គល អាត្មា តែក៏នាំមក នូវការពិបាកចិត្តពិបិន ផងដែរ ព្រោះថា អ្នកអាន អាន ដើម្បី រៀនផង, បង្រៀនផង, យល់ដឹងផង និង ការស្រមៃផង ដែល ផ្ទុសនា[2] វាតែងតែបង្កើត នូវវេទនាពីរខុស គ្នាបែបនេះឯង។ ដ្បិត ការសរសេរ ជួនមិនល្អ ជាស្នាដៃ ដែលនាំ អោយធុញ្ញទ្រាន់, តែក៏មានល្អ ដែលអ្នកអាន លើសការស្ទាន ទៅទៀត ផ្ទិត នូវស្នាដៃពិចិត្រ ជាប់នៅក្នុងដួងចិត្ត ហើយនាំ អារម្មណ៍ឆ្ពោះទៅក្នុងពិភពដែលមិនស្គាល់ និង អច្ឆរិយៈ។ ខ

---

[2] ផ្ទុសនា : contact.

អ្នកនិពន្ធ និង អ្នកអាន

ណ:ជាក់លាក់នោះឯង រាបង្កើត នូវសហចិត្តសុក្រិត[3] រវាងស្នាដៃ នៃអក្សរសិល្ប ជាមួយនឹង អ្នកអាន ដែលវាពន្លិចចិត្ត រំជួលរំភើប នៃអ្នកអានទៅក្នុងស្នាដៃអមត:។ រកន:ផុសនា[4] នេះឯង ជា រតិប្រាប្ត[5] នៃអ្នកនិពន្ធ ដែលជាអ្នកបង្កើត នូវពិភពនៃប្រលោមលោក ដើម្បីបំរើតែម្យ៉ាង នូវអារម្មណ៍ នៃអ្នកអាន។ ដំណូរ នៃអារម្មណ៍ជាអាច៖កំជាំង រវាង អ្នកនិពន្ធ និង អ្នកអាន ជាដំណូរជាប្រយោល នៃរូបកាយមែនពិត តែចិត្ត និងចិត្ត រាជាជំនួបប្រាកដមួយ នៅក្នុងពិភពសិប្បនិម្មិត កើតឡើងពីចំណង់បដិលោម[6]។ មួយជាអ្នកផ្សាយ, មួយទៀត ជាអ្នកចាប់យក រូបារម្មណ៍-អ្ករូប, សទ្ទារម្មណ៍-ត និង គន្ធារម្មណ៍-ក្លានក្លិន តែវត្ថុធាតុទាំងនោះ រាជាការប្រឌិត មានពិតនៅក្នុងសតិដឹង : រូបឆោមល្អ, តន្ត្រីពិរោះ និង ទឹកអប់ក្រអូប។ ដូច្នោះ ការសរសេរ រាជាព្រឹត្តិ នៃអក្សរសាស្ត្រ ដែលជាឧទ័យមួយ សំខាន់ នៃការចំរើន នៃមនុស្សជាតិ។

---

[3] សហចិត្តសុក្រិត : symbiose parfaite.

[4] រកន:ផុសនា : contact merveilleux.

[5] រតិប្រាប្ត : jouissance atteinte.

[6] ចំណង់បដិលោម : Désir réciproque.